ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

សំណុំរឿងរដ្ឋប្បវេណីលេខ:៣៨២

ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩

សាលក្រមលេខ: ១៤ "ខ"

ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកំពង់ស្ពឺ

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

**លោក [redacted] អនុប្រធាននិងជាចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ**

**ក្រឡាបញ្ជី**

**លោក លៀង តុលា ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ**

**-ដើមចោទឈ្មោះ** [redacted] **សុធាទិន** ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅ[redacted]។

**មេធាវីតំណាងដោយអាណត្តិមានលោក** [redacted]។

**-ចុងចម្លើយឈ្មោះ** [redacted] **សុធារី** ភេទស្រី អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅ[redacted]។

**ដែលមានកម្មវត្ថុបណ្តឹង**:

១.សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុធារី ភេទស្រី អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅ[redacted]។

២.អំពីកូន

-កូនស្រីចំនួន ពីរនាក់ មួយឈ្មោះ [redacted] លក្ខណា ភេទស្រី អាយុ ២៦ឆ្នាំ កើតថ្ងៃខែឆ្នាំកំណើត ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៤ និងទីពីរឈ្មោះ [redacted] ចន្ទបូតី ភេទស្រី អាយុ ១៨ឆ្នាំ កើតថ្ងៃខែឆ្នាំកំណើត ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០២ កូនស្រីទាំងពីរនាក់ពេញនីតិភាពផ្លូវច្បាប់អស់ហើយ កូនស្រីទាំងពីរនាក់បានសម្រេចចិត្តរស់នៅជាមួយម្តាយ ។

-ភាគី "ក" មានសិទ្ធិមកលេងសួរសុខទុក្ខបានគ្រប់ពេលវេលាតាមផ្លូវច្បាប់ ។

៣.ទ្រព្យសម្បត្តិរួមគ្មាន ។

៣-១.ដីភូមិនិងផ្ទះ ដែលកំពុងរស់នៅសព្វថ្ងៃស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ គឺបែងចែកជា ៣ ចំណែក ដោយកាត់ក្បាលដីខាងលិចផ្ទះ ដែលកំពុងរស់នៅនេះចំនួន ៤ម៉ែត្រ ប្រគល់ទៅឲ្យឈ្មោះ [redacted] សុធារី ចំណែកដីដែលនៅសល់ពីកាត់ឲ្យឈ្មោះ [redacted] សុធារី ត្រូវបែងចែកជា ២ចំណែក ឲ្យកូនស្រីទាំងពីរនាក់ គឺដីពាក់កណ្តាលប្រគល់ទៅឲ្យកូនស្រីទី១ ឈ្មោះ [redacted] លក្ខណា និងចំណែកដីដែលនៅសល់ពាក្យកណ្តាលទៀត រួមទាំងនឹងផ្ទះដែលកំពុងរស់នៅគឺប្រគល់ទៅឲ្យកូនស្រីទី២ឈ្មោះ [redacted] ចន្ទបូតី អាយុ ១៨ឆ្នាំ ។



Scanned with CamScanner

៣-២.ដីចំការទំហំប្រហែល ១.៥០ហិចតា(មួយហិចតាកន្លះ) ដែលមានព្រំប្រទល់:

-ខាងជើងទល់នឹងឈ្មោះ [redacted] លឹមហាវ -ខាងត្បូងទល់នឹងឈ្មោះ [redacted] ប៊ុនហាក់

-ខាងកើតទល់នឹងផ្លូវលំ -ខាងលិចទល់នឹងឈ្មោះ [redacted] ភ័ត់

ដែលមានទីតាំងស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ទៅឱ្យកូនស្រីទី១ ឈ្មោះ [redacted] លក្ខណា ។

៣-៣.ដីចំនួន ៤កន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដូចជា:

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០២ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០៥៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១៧ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

ដែលមានទីតាំងស្ថិតនៅភូមិក្រាំងតាចរ ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឱ្យកូនស្រីឈ្មោះ [redacted] ចន្ទ័ បូតី ។

៣-៤.ដីលំនៅដ្ឋាននៅជិតសាលាឃុំរុងរឿង ដែលមានព្រំប្រទល់:

-ខាងជើងទល់នឹងឈ្មោះ [redacted] ផា -ខាងត្បូងទល់នឹងឈ្មោះ អ៊ីវ

-ខាងកើតទល់នឹងឈ្មោះ ម៉ៅ -ខាងលិចទល់នឹងផ្លូវលំ

ដែលមានទីតាំងស្ថិតនៅភូមិរលាំងថ្លើង ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឱ្យចុងចម្លើយឈ្មោះ [redacted] សុធារី ។

៣-៥.ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០៥ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ស្ថិតនៅភូមិក្រាំងតាចរ ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឱ្យទៅចុងចម្លើយឈ្មោះ [redacted] សុធារី។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

**ទី១-ការទាមទាររបស់ដើមចោទ:**

១.សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុធារី ភេទស្រី អាយុ ៤៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ [redacted] ។

២.អំពីកូន

-កូនស្រីចំនួន ពីរនាក់ មួយឈ្មោះ [redacted] លក្ខណា ភេទស្រី អាយុ ២៦ឆ្នាំ កើតថ្ងៃខែឆ្នាំកំណើត ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៤ និងទីពីរឈ្មោះ [redacted] ចន្ទ័បូតី ភេទស្រី អាយុ ១៨ឆ្នាំ កើតថ្ងៃខែឆ្នាំកំណើត ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០២ កូនស្រីទាំងពីរនាក់ពេញនីតិភាពផ្លូវច្បាប់អស់ហើយ កូនស្រីទាំងពីរនាក់បានសម្រេចចិត្តរស់នៅជាមួយម្តាយ ។

-ភាគី "ក" មានសិទ្ធិមកលេងសួរសុខទុក្ខបានគ្រប់ពេលវេលាតាមផ្លូវច្បាប់ ។

៣.ទ្រព្យសម្បត្តិរួមគ្នា ។

៣-១.ដីភូមិនិងផ្ទះ ដែលកំពុងរស់នៅសព្វថ្ងៃស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ គឺបែងចែកជា ៣ ចំណែក ដោយកាត់ក្បាលដីខាងលិចផ្ទះ ដែលកំពុងរស់នៅនេះចំនួន ៤ម៉ែត្រ ប្រគល់ទៅឱ្យឈ្មោះ [redacted] សុធារី



Scanned with CamScanner

ចំណែកដីដែលនៅសល់ពីកាត់ឲ្យឈ្មោះ [redacted] សុធារី ត្រូវបែងចែកជា ២ចំណែក ឲ្យកូនស្រីទាំងពីរនាក់ គឺដីពាក់កណ្តាលប្រគល់ទៅឲ្យកូនស្រីទី១ ឈ្មោះ [redacted] លក្ខណា និងចំណែកដីដែលនៅសល់ពាកកណ្តាលទៀត រួមទាំងនឹងផ្ទះដែលកំពុងរស់នៅគឺប្រគល់ទៅឲ្យកូនស្រីទី២ឈ្មោះ [redacted] ចន្ទ័បូតី អាយុ ១៨ឆ្នាំ ។

៣-២.ដីចំការទំហំប្រហែល ១.៥០ហិចតា(មួយហិចតាកន្លះ) ដែលមានព្រំប្រទល់:

-ខាងជើងទល់នឹងឈ្មោះ [redacted] លឹមហាវ -ខាងត្បូងទល់នឹងឈ្មោះ [redacted] ប៊ុនហាក់

-ខាងកើតទល់នឹងផ្លូវលំ -ខាងលិចទល់នឹងឈ្មោះ [redacted] ភ័ត់

ដែលមានទីតាំងស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ទៅឲ្យកូនស្រីទី១ ឈ្មោះ [redacted] លក្ខណា ។

៣-៣.ដីចំនួន ៤កន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដូចជា:

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០២ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០៥៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១៧ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

ដែលមានទីតាំងស្ថិតនៅភូមិក្រាំងតាចរ ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឲ្យកូនស្រីឈ្មោះ [redacted] ចន្ទ័ បូតី ។

៣-៤.ដីលំនៅដ្ឋាននៅជិតសាលាឃុំរុងរឿង ដែលមានព្រំប្រទល់:

-ខាងជើងទល់នឹងឈ្មោះ [redacted] ធា -ខាងត្បូងទល់នឹងឈ្មោះ អ៊ីវ

-ខាងកើតទល់នឹងឈ្មោះ ម៉ៅ -ខាងលិចទល់នឹង ផ្លូវលំ

ដែលមានទីតាំងស្ថិតនៅភូមិរលាំងថ្លើង ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឲ្យចុងចម្លើយឈ្មោះ [redacted] សុធារី ។

៣-៥.ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០៥ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៤ ស្ថិតនៅភូមិក្រាំងតាចរ ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឲ្យទៅចុងចម្លើយឈ្មោះ [redacted] សុធារី។

**ទី២-ដំណើររឿងក្តី**

**ក-<u>ការអះអាងរបស់ភាគីដើមចោទ</u>**

-នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា កូនក្តីខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] សុធារី តាំងពីឆ្នាំ១៩៩៣ ដោយមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ។ ម្យ៉ាងវិញទៀត កូនក្តីខ្ញុំបាទនិងចុងចម្លើយមិនបានជំពាក់បំណុលគេនោះទេ។ ចំពោះកូនស្រីរបស់កូនក្តីខ្ញុំបាទឈ្មោះ [redacted] លក្ខណា និងឈ្មោះ [redacted] ចន្ទ័បូតី គឺសុទ្ធតែពេញនីតិភាពតាមផ្លូវច្បាប់អស់ហើយ ដូច្នេះហើយទើបកូនស្រីរបស់កូនក្តីខ្ញុំបាទ បានសម្រេចចិត្តដោយខ្លួនឯង សុខចិត្តរស់នៅជាមួយម្តាយ ។ ក្រោយពីកូនក្តីរបស់ខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធអស់រយៈពេលជាច្រើនឆ្នាំមកនេះ តែងតែមានភាពល្អក់កករ និងភាពរកាំរកូស ពុំមានការយល់ចិត្តរវាងគ្នានឹងគ្នាឡើយ រហូតមកដល់ពេលនេះ កូនក្តីខ្ញុំបាទអស់មនោសញ្ចេតនានឹងគ្នាជាប្តីប្រពន្ធទៀតហើយ។



Scanned with CamScanner

ខ-<u>ការអះអាងរបស់ភាគីចុងចម្លើយ</u>

-នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុ និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា នាងខ្ញុំមិនឯកភាពត្រង់ចំណុចទី១ នោះទេ គឺមិនព្រមលែងលះនោះទេ ព្រោះនាងខ្ញុំមិនដែលមានជម្លោះ ឬបញ្ហាអ្វីជាមួយគ្នានោះទេ ចំណុចទី២ និងចំណុចទី៣ នាងខ្ញុំឯកភាពតាមការស្នើសុំរបស់ដើមចោទ និងនាងខ្ញុំសុំទឹកប្រាក់ពីដើមចោទចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ដោយសារតែដីរបស់ដើមចោទមានជាច្រើនកន្លែងទៀត ដែលជាចំណែករួមរកស៊ីជាមួយនាងខ្ញុំ ។

**គ-ចំណុចវិវាទ:** ដើមចោទបដិសេធការទាមទារប្រាក់ ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក និងចុងចម្លើយបដិសេធការលែងលះ។

**<u>សំអាងហេតុ</u>**

-ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា កូនក្ដីខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] សុធារី តាំងពីឆ្នាំ១៩៨៣ ដោយមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ។ ម្យ៉ាងវិញទៀត កូនក្ដីខ្ញុំបាទនិងចុងចម្លើយមិនបានជំពាក់បំណុលគេនោះទេ។ ចំពោះកូនស្រីរបស់កូនក្ដីខ្ញុំបាទឈ្មោះ [redacted] **លក្ខណា** និងឈ្មោះ [redacted] **ចន្ទ័បូតី** គឺសុទ្ធតែពេញនីតិភាពតាមផ្លូវច្បាប់អស់ហើយ ដូច្នេះហើយទើបកូនស្រីរបស់កូនក្ដីខ្ញុំបាទ បានសម្រេចចិត្តដោយខ្លួនឯង សុខចិត្តរស់នៅជាមួយម្ដាយ ។ ក្រោយពីកូនក្ដីរបស់ខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ជាប្ដីប្រពន្ធអស់រយៈពេលជាច្រើនឆ្នាំមកនេះ តែងតែមានភាពល្អក់កករ និងភាពរកាំរកូស ពុំមានការយល់ចិត្តរវាងគ្នានឹងគ្នាឡើយ រហូតមកដល់ពេលនេះ កូនក្ដីខ្ញុំបាទអស់មនោសញ្ចេតនានឹងគ្នាជាប្ដីប្រពន្ធទៀតហើ។

-ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នាងខ្ញុំមិនឯកភាពត្រង់ចំណុចទី១ នោះទេ គឺមិនព្រមលែងលះនោះទេ ព្រោះនាងខ្ញុំមិនដែលមានជម្លោះ ឬបញ្ហាអ្វីជាមួយគ្នានោះទេ ចំណុចទី២ និងចំណុចទី៣ នាងខ្ញុំឯកភាពតាមការស្នើសុំរបស់ដើមចោទ និងនាងខ្ញុំសុំទឹកប្រាក់ពីដើមចោទចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ដោយសារតែដីរបស់ដើមចោទមានជាច្រើនកន្លែងទៀត ដែលជាចំណែករួមរកស៊ីជាមួយនាងខ្ញុំ ។

-ដើមចោទឈ្មោះ [redacted] **សុធាវិន** និងចុងចម្លើយឈ្មោះ [redacted] **សុធារី** បានឯកភាពត្រង់ចំណុចទី ២ និងចំណុចទី ៣ ដូចតុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

-ចុងចម្លើយឈ្មោះ [redacted] **សុធារី** បានទាមទារប្រាក់ចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ពុំមានមូលហេតុណាមួយសមរម្យមកបញ្ជាក់ឱ្យតុលាការជឿជាក់បានឡើយ ដូចនេះតុលាការគប្បីលើកមកពិចារណាសម្រេចតាមច្បាប់។

-ចុងចម្លើយឈ្មោះ [redacted] **សុធារី** មិនបានឯកភាពលែងលះតាមការតាមពាក្យសុំរបស់ដើមចោទនោះទេ ដូចនេះតុលាការគប្បីលើកមកពិចារណាសម្រេចតាមច្បាប់។

-កូនស្រីទាំងពីរនាក់ឈ្មោះ [redacted] **លក្ខណា** និងឈ្មោះ [redacted] **ចន្ទ័បូតី** គឺពេញនីតិភាពក្នុងការសម្រេចចិត្ត និងគ្រប់គ្រងទ្រព្យសម្បត្តិដែលទទួលបានពីការបែងចែកចំណែករបស់ឪពុកម្ដាយ ដូចនេះតុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់ដើមចោទឈ្មោះ [redacted] **សុធាវិន** និងចុងចម្លើយឈ្មោះ [redacted] **សុធារី** ។

<u>ការពិនិត្យភស្តុតាង:</u>

-សៀវភៅគ្រួសាររបស់ឈ្មោះ [redacted] សុធាវិន N04655ក.ស្ក

-សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ក្នុងសៀវភៅអាពាហ៍ពិពាហ៍លេខ ០១/០១៤ និងសំបុត្រអាពាហ៍ពិពាហ៍លេខ ១៨ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ។

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] សុធាវិន

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] សុធារី

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] លក្ខណា

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ [redacted] ចន្ទ័បូតី

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០២ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០៥៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១៧ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០៥ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៤ ។

-ប្រាក់ប្រដាប់ក្ដីអនុវត្តតាមបញ្ញត្តិច្បាប់មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សាលាដំបូងខេត្តកំពង់ស្ពឺ</u>

## <u>វិនិច្ឆ័យសេចក្ដី</u>

**១.**ផ្ដាច់ចំណងអាពាហ៍ពិពាហ៍រវាងដើមចោទឈ្មោះ [redacted] **សុធាវិន** និងចុងចម្លើយឈ្មោះ [redacted] **សុធារី** ចាប់ពីពេលនេះតទៅ។

**២.**បែងចែកដីនិងផ្ទះស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឱ្យចុងចម្លើយឈ្មោះ [redacted] **សុធារី** កូនស្រីឈ្មោះ [redacted] **លក្ខណា** និងកូនស្រីឈ្មោះ [redacted] **ចន្ទ័បូតី** ដូចជា

ក.ប្រគល់សិទ្ធិគ្រប់គ្រងដីស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ក្បាលដីខាងលិចផ្ទះប្រវែង ៤(បួន)ម៉ែត្រ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **សុធារី** ជាម្ចាស់កម្មសិទ្ធិ ។

ខ.ប្រគល់សិទ្ធិគ្រប់គ្រងដីស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឱ្យទៅកូនស្រីឈ្មោះ [redacted] **លក្ខណា** ជាម្ចាស់កម្មសិទ្ធិ ។

គ.ប្រគល់សិទ្ធិគ្រប់គ្រងដីនិងផ្ទះស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឱ្យទៅកូនស្រីឈ្មោះ [redacted] **ចន្ទ័ បូតី** ជាម្ចាស់កម្មសិទ្ធិ ។

៣.ប្រគល់សិទ្ធិគ្រប់គ្រងដីចំការទំហំប្រហែល ១.៥០ហិចតា(មួយហិចតាកន្លះ) ដែលមានព្រំប្រទល់: ខាងជើងទល់នឹងឈ្មោះ [redacted] លឹមហាវ, ខាងត្បូងទល់នឹងឈ្មោះ [redacted] ប៊ុនហាក់, ខាងកើតទល់នឹងផ្លូវលំ, ខាងលិចទល់នឹងឈ្មោះ [redacted] វ៉ាត់ ដែលមានទីតាំងស្ថិតនៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ទៅឱ្យកូនស្រីឈ្មោះ [redacted] **លក្ខណា** ជាម្ចាស់កម្មសិទ្ធិ ។

៤.ប្រគល់សិទ្ធិគ្រប់គ្រងដីចំនួន ៤កន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដូចជា:

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០២ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០៥៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។

វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០១៧ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ។



Scanned with CamScanner

ដែលមានទីតាំងស្ថិតនៅភូមិក្រាំងតាចរ ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឲ្យកូនស្រីឈ្មោះ [redacted] **ចន្ទ័បុតី** ជាម្ចាស់កម្មសិទ្ធិ។

**៥.**ប្រគល់សិទ្ធិគ្រប់គ្រងដីលំនៅដ្ឋាននៅជិតសាលាឃុំរុងរឿង ដែលមានព្រំប្រទល់ ខាងជើងទល់នឹងឈ្មោះ [redacted] ធា, ខាងត្បូងទល់នឹងឈ្មោះ អ៊ុំវ, ខាងកើតទល់នឹងឈ្មោះ ម៉ៅ, ខាងលិចទល់នឹងផ្លូវលំ ដែលមានទីតាំងស្ថិតនៅភូមិរលាំងធ្វើង ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឲ្យចុងចម្លើយឈ្មោះ [redacted] **សុធារី** ។

**៦.**ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៥០៨០៥១០-០០០៥ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ស្ថិតនៅភូមិក្រាំងតាចរ ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ប្រគល់ឲ្យទៅចុងចម្លើយឈ្មោះ [redacted] **សុធារី**។

**៧.**ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផល និងប្រកាសជាសាធារណៈនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២០ ចំពោះមុខគូភាគី ទុកសិទ្ធប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពង់ស្ពឺ.ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner